**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៧៦៩

ចុះថ្ងៃទី ៣០-០៦-១៩៩៩

សាលក្រមលេខ: ០៣'ង'

ចុះថ្ងៃទី ២៥ កុម្ភៈ ២០០០

## <u>**គាននាមប្រជារាស្ត្រខ្មែរ**</u>

តុលាការក្រុងភ្នំពេញបង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំនុំជ្រះ នៃរដ្ឋកម្ពុជាប្រកាសអោយប្រើតាមក្រឹត្យលេខ : ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈនៅបន្ទប់ជំនុំជំរះ នៃតុលាការក្រុងភ្នំពេញ នាថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ :

<u>**ចៅក្រមជំនុំជំរះ**</u>

- លោក ***ម ឃច*** ចៅក្រម

<u>**តំណាងអយ្យការ**</u>

- លោក ***ខ សរ*** ព្រះរាជអាជ្ញារង

<u>**ក្រឡាបញ្ជីសវនាការ**</u>

- លោក ***ម សគរ***

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខៈ៧៦៩ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលមានជនជាប់ចោទ :

១-ឈ្មោះ ***ម សអ*** ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ កើតនៅ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ក្រុមទី ១៩ ឃុំត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរ និស្សិតពាណិជ្ជសាស្ត្រ នៅលីវ ។ ឪពុកឈ្មោះ ***ម សទ*** (រ) ម្តាយឈ្មោះ ***ឃ គ*** (រ) ។ ទោសពីមុនគ្មាន ក្រៅឃុំ *(រត់គេចខ្លួន)* ។

២-ឈ្មោះ ***ឃ ទគ*** ហៅអាអ៊ិក ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅ សង្កាត់លេខ ៣ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១០៣ E₃ ក្រុងទី ៧ ភូមិ ២ សង្កាត់មនោរម្យ ខណ្ឌ៧មករា ក្រុងភ្នំពេញ មុខរបរ គ្មាន នៅលីវ ។ ឪពុកឈ្មោះ ***គ មម*** (រ) ម្តាយឈ្មោះ ***គ ទ*** (រ) ។ ទោសពីមុនគ្មាន នៅក្រៅឃុំ *(រត់គេចខ្លួន)*



Scanned with CamScanner

៣-ឈ្មោះ ***ថ សត*** ភេទប្រុស ជាតិខ្មែរ អាយុ ២២ឆ្នាំ កើតនៅឃុំគោកតាសុក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៣៥ $E_2$ ផ្លូវលេខ ២១៥ ក្រុមទី ១ សង្កាត់ផ្សារដេប៉ូ ១ ខណ្ឌទួលគោក ក្រុងភ្នំពេញ មុខរបរ សិស្ស នៅលីវ ។ ឪពុកឈ្មោះ ***ថ ទថ*** (រ) ម្តាយឈ្មោះ ***ម សអ*** (រ) ។ ទោសពីមុនគ្មាន នៅក្រៅឃុំ (*រត់គេចខ្លួន*)។ ជនជាប់ចោទពីបទភេរវកម្ម ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២នៃច្បាប់ស្តីពីការផ្តន្ទាអំពើភេរវកម្ម ។

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មាន**

តុលាការក្រុងភ្នំពេញបានសំរេច រោមដីកាលេខ ២៥៥ ត.ព្រ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០០ ចាត់តាំងលោក ***ត សឋ*** ជាមេធាវីការពារអោយជនជាប់ចោទទាំងបីរូបខាងលើ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**

កាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ វេលាម៉ោង ៣ ជាង ឈ្មោះ ***អ យ*** ឈ្មោះ ***គ ឋ*** ឈ្មោះ ***ម សអ*** ឈ្មោះ ***យ ទត*** និង ឈ្មោះ ***ថ សត*** បាននាំគ្នាជិះរថយន្តកាមរី (CAMARY) ដែលជួលពីឈ្មោះ ***ថ ឲ*** នាំគ្នាទៅស៊ីផឹកនៅតាខ្មៅ ក្រោយពេលស៊ីផឹករួចក៏នាំគ្នាត្រឡប់មកភ្នំពេញវិញ សំរាកនៅសណ្ឋាគារចំប៉ាមាស ដោយជួលបន្ទប់២ បន្ទប់មួយឈ្មោះ ***គ ឋ*** និងឈ្មោះ ***អ យ*** ដេកបន្ទប់ជាមួយគ្នា ចំណែកឯឈ្មោះ ***យ ទត, ថ សត*** និង ឈ្មោះ ***ម សអ*** ដេកជាមួយគ្នាក្នុង បន្ទប់មួយផ្សេងទៀត ។ ក្រោយពីបានរកស្រីម្នាក់មកប្រគល់អោយ ***គ ឋ*** និង ***អ យ*** រួចមកឈ្មោះ ***យ ទត, ថ សត*** និង ឈ្មោះ ***ម សអ*** បាននាំគ្នា ចាប់ឈ្មោះ ***យ បទ*** ជិះតទារប្រាក់ រួចហើយសំលាប់ ដឹកយកទៅទំលាក់ចោលនៅវត្តសន្សំកុសល ។

-បានឃើញរបាយការណ៍លេខ ២៨៥ រប.ក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ ។

-បានឃើញរបាយការណ៍លេខ ៤០៧ ល.ស ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់ស្នងការនគរបាលរាជធានីភ្នំពេញ ។

-បានឃើញកំនត់ហេតុត្រួតពិនិត្យសាកសពចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់ការិយាល័យបច្ចេកទេសនគរបាលព្រហ្មទណ្ឌរាជធានីភ្នំពេញ ។

-បានឃើញដីកាលើកលែងចោទប្រកាន់លេខ ៥៣១២ ត.ព្រ និង លេខ ៥៣១៣ ត.ព្រ ចុះ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ៧៧ ត.ព្រ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ របស់ចៅក្រមស៊ើបអង្កេត ។



Scanned with CamScanner

## នៅចំពោះចុងចោទនៅពេលសាកសួរ

-តាមការអានចំលើយរបស់ *គ ឆ* បានឃើញបញ្ជាក់ថា : ខ្លួនមិនបានចូលរួមប្រព្រឹត្តអំពើភេរវកម្ម ចាប់ជំរិតទារយកប្រាក់នោះឡើយ ដោយខ្លួន និង ឈ្មោះ *អ ឃ* គ្រាន់តែបានដើរលេង ជាមួយមិត្តភក្តិ ឈ្មោះ *ឃ ចគ, ម សអ* និង ឈ្មោះ *ខ សគ* នៅតាខ្មៅហើយពេលត្រឡប់មកពីតាខ្មៅវិញ ខ្លួននិងឈ្មោះ *អ ឃ* ដេកនៅសណ្ឋាគារចំប៉ាមាស បន្ទប់មួយផ្សេង ចំណែកមិត្តភក្តិខ្លួន ៣ នាក់ទៀតដេកនៅបន្ទប់មួយផ្សេងទៀត ។ ក្រោយពីបានជួលបន្ទប់ដេកហើយខ្លួន និង ឈ្មោះ *អ ឃ* នៅមើលទូរទស្សន៍ ចំណែកឈ្មោះ *ម សអ* ឈ្មោះ *ឃ ចគ* និងឈ្មោះ *ខ សគ* ដែលនៅបន្ទប់ផ្សេងបាននាំគ្នានៅក្រៅ លុះដល់ពេលត្រឡប់មកវិញ អ្នកទាំងបីនាក់បានយកស្រីម្នាក់មកអោយខ្លួន និង ឈ្មោះ *អ ឃ* ដេកលេងដោយពេលទាំង ៣ យកស្រីមកអោយនោះ ខ្លួនពុំបានចាប់អារម្មណ៍ថាមាន់គ្នាប៉ុន្មាននាក់ នោះឡើយ ។ តាមចំលើយរបស់ *គ ឆ* ក៏បានបញ្ជាក់ថែមទៀតផងដែរថា : ប្រាក់ដែលសមត្ថកិច្ចដកហូតនោះ ជាប្រាក់ក្រុមគ្រួសាររបស់ខ្លួន មិនមែនជាប្រាក់ដែលបានមកពីការចាប់ជំរិតអ្វីនោះឡើយ ។

-តាមការអានចំលើយរបស់ឈ្មោះ *អ ឃ* បានបញ្ជាក់ថាកាលពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៩ ខ្លួននិងមិត្តភក្តិមានឈ្មោះ *ខ សគ* ឈ្មោះ *ម សអ* ឈ្មោះ *ឃ ចគ* និងឈ្មោះ *គ ឆ* បាននាំគ្នាជិះរថយន្តកាមរី ទៅស៊ីផឹកនៅតាខ្មៅ រួចត្រឡប់មកវិញ នាំគ្នាជួលសណ្ឋាគារចំប៉ាមាស មួយបន្ទប់តំលៃ ១០ ដុល្លារ ដោយខ្លួន និង ឈ្មោះ *គ ឆ* នៅបន្ទប់ជាមួយគ្នា ចំណែកឈ្មោះ *ខ សគ* ឈ្មោះ *ម សអ* ឈ្មោះ *ឃ ចគ* ដេកនៅបន្ទប់ផ្សេង ហើយនៅពេលដែលខ្លួនចូលដេកជាមួយឈ្មោះ *គ ឆ* មិត្តភក្តិខ្លួន ៣ នាក់ទៀតចេញទៅក្រៅបាត់ លុះពេលត្រឡប់មកវិញអ្នកទាំង ៣ បានយកស្រីម្នាក់មួយអោយខ្លួន និង ឈ្មោះ *គ ឆ* ដេកលេង ។ លុះពេលភ្លឺឡើងខ្លួនបានឃើញឈ្មោះ *ខ សគ* គ្រាមនុស្សម្នាក់ចូលឡានរួច វាបើកទៅបាត់មួយ សន្ទុះក្រោយមកត្រឡប់មកវិញមក យកខ្លួន និង ឈ្មោះ *គ ឆ* ទៅផ្ទះ តែខ្លួនមិនបានឃើញមនុស្សម្នាក់នោះទេ នៅពេលត្រឡប់មកវិញ ហើយខ្លួនបានសួរ តែពួកវាថាឯងកុំចេះដឹងអ្វី ។

-តាមចំលើយរបស់ *ខ ព* បានបញ្ជាក់ថា : កាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ មានជន ៤ នាក់មកជួលរថយន្តខ្លួនដោយពេលធ្វើកិច្ចសន្យាជួលនោះ ខ្លួនបានស្គាល់ឈ្មោះ *អ ឃ* និងឈ្មោះ *គ ឆឆ* ចំណែក ០២ នាក់ទៀតខ្លួនពុំស្គាល់ទេ ។

-តាមការអានចំលើយរបស់ឈ្មោះ *គ ចា* បានបញ្ជាក់ថា : នៅ ថ្ងៃ ខែ មិនចាំ ឆ្នាំ ១៩៩៩ សមត្ថកិច្ចបានហៅកូនខ្លួនឈ្មោះ *គ ឆ* ទៅធ្វើការសាកសួរ ដោយពេលទៅនោះ កូនខ្លួនម្នាក់ទៀត ឈ្មោះ *គ គ* ជាអ្នកជូនទៅលុះក្រោយមកឃើញកូនឈ្មោះ *គ គ* មកសុំប្រាក់ពីខ្លួនចំនួន ២ ៩០០ ដុល្លា ថាយកទៅប្រគល់ជូនសមត្ថកិច្ច ដោយខ្លួនមានការភ័យខ្លាចកូនខ្លួនឈ្មោះ *គ ឆ* មានរឿងរ៉ាវ ខ្លួនសុខចិត្តយកប្រាក់ពីផ្ទះជូនសមត្ថកិច្ច ដោយខ្លួនមិនដឹងថា កូនខ្លួនមានជាប់ទាក់ទិននឹងរឿងអ្វីនោះឡើយ ។ តាមចំលើយរបស់ឈ្មោះ *គ ចា* ក៏បានបញ្ជាក់ថែមទៀត ផងដែរថាប្រាក់ ២ ៩០០ ដុល្លា ពិតជាប្រាក់របស់ខ្លួនពិតប្រាកដមែន ហើយប្រសិនបើមិនមានទាក់ទងអ្វីទេ ខ្លួនសុំយកប្រាក់នេះទៅប្រើប្រាស់វិញ ។



Scanned with CamScanner

-តាមចំលើយរបស់ឈ្មោះ ***ឥ ឥ*** បានឆ្លើយបញ្ជាក់ថា ខ្លួនបានមកយកលុយពីម្ដាយខ្លួនចំនួន ២ ៩០០ ដុល្លា ទៅប្រគល់ជូនសមត្ថកិច្ចប្រាកដមែន ដោយភ័យខ្លាចសមត្ថកិច្ចឃាត់ខ្លួនប្អូនរបស់ខ្លួន ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា : មានភស្ដុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើជន ជាប់ចោទឈ្មោះ ***ម សអ*** ភេទប្រុស អាយុ២០ឆ្នាំ ឈ្មោះ ***ឃ ទគ*** ហៅអាអ៊ុក ភេទប្រុស អាយុ២២ឆ្នាំ និងឈ្មោះ ***៩ សគ*** ភេទប្រុស អាយុ ២២ឆ្នាំ ពីបទ ភេរវកម្ម ប្រព្រឹត្ត នៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ។

-បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្ដន្ទាទោសតាមមាត្រា ២ នៃច្បាប់ស្ដីពីការផ្ដន្ទាទោសអំពើភេរវកម្ម តំណាងអយ្យការសុំតំកល់បទចោទ ទុកជាបានការ និង ស្នើរសុំអោយតុលាការសំរេចផ្ដន្ទាទោសលើ ជនជាប់ចោទទាំង ៣ រូបខាងលើ ក្នុងម្នាក់ៗកំនត់អស់មួយជីវិត ។

-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ក្រៅពីចំលើយរបស់ឈ្មោះ ***ឥ ៩*** និង ឈ្មោះ ***អ ឃ*** ពុំមានភស្ដុតាងអ្វីផ្សេងណាមួយបញ្ជាក់ថា ជនជាប់ចោទទាំង ០៣ រូបនេះ បានប្រព្រឹត្តអំពើភេរវកម្ម ចាប់ជំរិតជនរងគ្រោះ ឈ្មោះ ***ឃ ឃទ*** រួចសំលាប់ចោលនោះឡើយ ។ ថ្វីត្បិតតែមានជនរងគ្រោះស្លាប់ក៏ពិតមែនក៏ដោយ តែពុំមានសាក្សីណាឃើញដោយផ្ទាល់ថាជនជាប់ចោទទាំងបីរូបនោះ ធ្វើសកម្មភាពចាប់ជំរិតជនរងគ្រោះ រួចសំលាប់ដោយប្រើមធ្យោបាយរបៀបណានោះដែរ សូម្បីតែទំនាក់ទំនងក្នុងការទារយកលុយពី គ្រួសាររបស់ជនរងគ្រោះ តាមវិធីណានោះក៏គ្មានដែរ ហេតុនេះសូមលោកចៅក្រមមេត្តាពិនិត្យ និង សំរេចអោយជនជាប់ចោទទាំងបីរូបបានផុតពីបទចោទប្រកាន់តាមផ្លូវច្បាប់ ដោយសេចក្ដីអនុគ្រោះ ។

- ក្រោយពីបានស្ដាប់ការអានចំលើយរបស់សាក្សី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យ និង ពិចារណាត្រឹមត្រូវតាមច្បាប់

## តុលាការក្រុងភ្នំពេញ

## យល់ឃើញថា

-ជនជាប់ចោទឈ្មោះ ***ម សអ*** ភេទប្រុស អាយុ ២០ឆ្នាំ ឈ្មោះ ***ឃ ទគ*** ភេទប្រុស អាយុ ២២ឆ្នាំ និង ឈ្មោះ ***៩ សគ*** ភេទប្រុស អាយុ ២២ ឆ្នាំ មានសមត្ថភាព និង កាយសម្បទាគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវពេញទីនៅចំពោះមុខច្បាប់ព្រហ្មទណ្ឌ ។

-អំពើ និង សកម្មភាពរបស់ជនជាប់ចោទទាំងបីរូប ដែលបានប្រព្រឹត្តឡើងធ្វើអោយប៉ះពាល់ដោយផ្ទាល់ទៅលើទ្រព្យសម្បត្តិអាយុជីវិតអ្នកដទៃ និងសណ្ដាប់ធ្នាប់សាធារណៈដែលច្បាប់ស្ដីពីការផ្ដន្ទាទោសអំពើភេរវកម្ម បានហាមឃាត់ ។



Scanned with CamScanner

ផលវិបាក នៃអំពើនេះ បានជះឥទ្ធិពលអាក្រក់ដល់សង្គមជាតិ និង បានធ្វើអោយប្រជារាស្ត្រទូទៅ មានការតក់ស្លុត និង ភ័យខ្លាចយ៉ាងក្រៃលែង ។

-កាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ មានអំពើរចាប់ជំរិតលើជនរងគ្រោះឈ្មោះ *ឃ ចទ* ដោយបានសំរេចផលហើយ ការជំរិតប្រាក់នេះបានបណ្តាលអោយជនរងគ្រោះ ទទួលរងមរណភាពដោយសារអំពើរបស់ជនល្មើសមួយក្រុម ។

-តាមការឆ្លើយដាក់បន្ទុករបស់សាក្សី ២ នាក់ មានឈ្មោះ *គ ឌ* និង ឈ្មោះ *អ ឃ* ដែលជាអ្នកដឹងឮ អំពីរឿងនេះថា អំពើចាប់ជំរិតលើជនរងគ្រោះ បានបង្កឡើងដោយឈ្មោះ *ម សអ, ឃ ទគ* និង ឈ្មោះ *ខ សគ* ។

-ជនជាប់ចោទទាំងបីរូប ធ្វើសកម្មភាពជំរិតទារប្រាក់ពីគ្រួសារជនរងគ្រោះ ហើយសំលាប់ជនរងគ្រោះដោយប្រើអំពើព្រៃផ្សៃយកខ្សែរស្បែកជើង ចងដៃ ចងជើង និង ចងរឹតក រួចដឹកយកសាកសពជនរងគ្រោះទៅទំលាក់ចោលនៅក្បែរវត្តសន្សំកុសល ហើយក្រោយពេលប្រព្រឹត្តជនជាប់ចោទទាំងបីរូបនេះបានរត់គេចខ្លួនបាត់ ដែលអាចបញ្ជាក់បានថា : ជនទាំងបីពិត ជាបានប្រព្រឹត្តអំពើភេរវកម្មប្រាកដមែន ។

-មានភស្តុតាង និង ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ *ម សអ, ឃ ទគ* និង ឈ្មោះ *ខ សគ* ពីបទភេរវកម្មប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ។

-ឈ្មោះ *គ ឌ* និង ឈ្មោះ *អ ឃ* ជាជនជាប់ទាក់ទិនក្នុងរឿងក្តីនេះ ត្រូវបានតុលាការសំរេចលើកលែងចោទប្រកាន់តាមដីកាលេខ ៥៣១២ ត.ព្រ និង លេខ ៥៣១៣ ត.ព្រ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ហើយបច្ចុប្បន្នដីកាលើកលែងចោទប្រកាន់នេះបានចូលជាស្ថាពររួចហើយដែរ ដែលជាហេតុធ្វើអោយតុលាការ មិនអាចលើកយកអញ្ញត្តកម្មក្នុងរឿងក្តីនេះ មកធ្វើការសំរេចសេចក្តីសារជាថ្មីទៀតនោះឡើយ ។

-វត្ថុតាងមានប្រាក់ចំនួន ២ ៥០០ ដុល្លារ ដែលមានសមត្ថកិច្ចបានដកហូតពីឈ្មោះ *គ ឌ* ពុំមានពាក់ពន្ធ័ និងបទល្មើសដែលបានចោទប្រកាន់ឡើយ ហើយវត្ថុតាងនេះ ត្រូវបានចៅក្រមស៊ើបសួរ មិនបានសំរេចប្រគល់អោយម្ចាស់ដើមវិញតាមដីកាសំរេចលើកលែងចោទប្រកាន់ឡើយ ដូចនេះគប្បីតុលាការធ្វើការពិចារណា សំរេចប្រគល់អោយម្ចាស់ដើមវិញដោយចាប់គិតពីពេលចេញសេចក្តីសំរេច ។

-គ្រួសារជនរងគ្រោះក្នុងករណីនេះបានអវត្តមានតាំងពីដំណាក់កាលស៊ើបសួរ រហូតដល់ពេលជំនុំជំរះ ដែលចាត់ទុកថា ពុំទាន់មានសំណូមពរក្នុងការប្តឹងសុំសិទ្ធិតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីដែលគប្បីតុលាការរក្សាសិទ្ធិនេះ ដល់គ្រួសារជនរងគ្រោះ ក្នុងការប្តឹងសុំសំណងរដ្ឋប្បវេណី នាពេលក្រោយ ។

-ជនជាប់ចោទបានអវត្តមាននាពេលសាវនាការ តែតុលាការបានធ្វើការបង្គាប់អោយចូលខ្លួនហើយ ដែលចាត់ទុកថាតុលាការអាចដំណើរការនីតិវិធីដោយកំបាំងមុខបាន ។



Scanned with CamScanner

**សាលាដំបូងខេត្តក្រុងភ្នំពេញ**

**សំរេចដីកាវិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើឈ្មោះ —

-ឈ្មោះ ***ម សអ*** ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ កើតនៅ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ក្រុមទី ១៩ ឃុំត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរ និស្សិតពាណិជ្ជសាស្ត្រ នៅលីវ ។ ឪពុកឈ្មោះ ***ម សច***(រ) ម្តាយឈ្មោះ ***ឌ គ*** (រ) ។ ទោសពីមុនគ្មាន ។

-ឈ្មោះ ***ឃ ចត*** ហៅអារិុក ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ កើតនៅ សង្កាត់លេខ ៣ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១០៣ $E_3$ ក្រុងទី៧ ភូមិ២ សង្កាត់មនោរម្យ ខណ្ឌ៧មករា ក្រុងភ្នំពេញ មុខរបរ គ្មាន នៅលីវ ។ ឪពុកឈ្មោះ ***ត ឋម*** (រ) ម្តាយឈ្មោះ ***គ ៩***(រ) ។ ទោសពីមុនគ្មាន ។

-ឈ្មោះ ***៩ សត*** ភេទ ប្រុស ជាតិ ខ្មែរ អាយុ ២២ ឆ្នាំ កើតនៅឃុំគោកតាសុក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៣៥ $E_2$ ផ្លូវលេខ ២១៥ ក្រុមទី ១ សង្កាត់ផ្សារដេប៉ូ ១ ខណ្ឌទួលគោក ក្រុងភ្នំពេញ មុខរបរសិស្ស នៅលីវ ។ ឪពុកឈ្មោះ ***៩ ៩៩***(រ) ម្តាយឈ្មោះ ***ម សអ***(រ) ។ ទោសពី មុនគ្មាន ។

***ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗម្ភៃឆ្នាំ (២០ឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបានមកទទួលទោសតទៅ ។***

***ពីបទប្រព្រឹត្តអំពើភេរវកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ។***

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ។

២-រក្សាសិទ្ធិអោយជនរងគ្រោះ ក្នុងករណីនេះ ក្នុងការប្តឹងទាមទារសំណងព្យសនកម្មនាពេលក្រោយ នៅតុលាការរដ្ឋប្បវេណី ។

៣-វត្ថុតាងដែលមានប្រាក់ចំនួន ២ ៩០០ ដុល្លារអាមេរិក ត្រូវប្រគល់អោយឈ្មោះ ***គ ៩*** ដែលជាម្ចាស់ប្រាក់វិញ ចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ ។

៤-សាលក្រមនេះជំនុំ និង ប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទទាំងបីរូប និង ជនរងគ្រោះ ។

***ទុករយៈពេលប្តឹងទាស់ និងលើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។***

ក្រឡាបញ្ជី ***ម សតរ***

ចៅក្រមជំនុំជំរះ ***ម ឧច***